ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី

ឆ្នាំទី ០៤ លេខ ១១

# ព្រឹត្តិបត្រព័ត៌មាន

## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

# សកម្មភាព ការងារ

ECOSOCC

ក ស វ



# Work Activities

ប្រចាំខែវិច្ឆិកា ឆ្នាំ២០១១



# មាតិកាអត្ថបទ

## កិច្ចប្រជុំជំនាញបច្ចេកទេស រវាងក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ក្រុមប្រឹក្សាអ្នកច្បាប់ និងតំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល


| ល.រ | ឈ្មោះអត្ថបទ | លេខទំព័រ |
|---|---|---|
| ១- | សេចក្តីព្រាងកម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិល | ១ |
| ២- | សេចក្តីព្រាងអនុក្រឹត្យស្តីពីការអនុវត្តច្បាប់សវនកម្ម | ៣ |
| ៣- | សេចក្តីព្រាងអនុក្រឹត្យស្តីពីការផ្តល់ឋានៈសាស្ត្រាចារ្យក្នុងវិស័យអប់រំ | ៥ |
| ៤- | សេចក្តីព្រាងច្បាប់ស្តីពីសហជីព | ៧ |
| ៥- | សកម្មភាពដទៃទៀតរបស់ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ | ៩ |

# សេចក្តីព្រាងកម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិល



កាលពីថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១១ វេលាម៉ោង៨:៣០ នាទី និងវេលាម៉ោង១៥:00 នៅទីស្តីការគណៈរដ្ឋមន្ត្រីមាន បើកអង្គប្រជុំជំនាញបច្ចេកទេស ក្រោមអធិបតីភាព ឯកឧត្តម **កែវ វិចិត្រ** សមាជិកក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌( ECOSOCC ) និង ឯកឧត្តម **ផៃ សុខខេង** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សាលើ**សេចក្តីព្រាងកម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិល** ដោយមានការអញ្ជើញចូលរួមពីសំណាក់ សមាជិក អគ្គលេខាធិការរង និងមន្ត្រីនៃក.ស.វ. សមាជិក និងមន្ត្រីនៃក្រុមប្រឹក្សាអ្នកច្បាប់ តំណាងទីស្តីការគណៈរដ្ឋមន្ត្រី តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល តំណាងខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី **សុខ អាន** មន្ត្រីជំនាញនៃទីស្តីការគណៈរដ្ឋមន្ត្រី និងតំណាងក្រសួងផែនការ។

ដោយផ្អែកលើស្មារតីនិងខ្លឹមសារនៃ ផ.យ.អ.ជ. បច្ចុប្បន្នកម្ម ២០០៩-២០១៣ កម្មវិធីវិនិយោគសាធារណៈបីឆ្នាំរំកិល( ក.វ.ស. ) លើកនេះត្រូវបានរៀបចំឡើងដោយមានការគិតគូរដល់កត្តាចម្បង និងស្ថានភាពជាក់ស្តែងបីសំខាន់ៗពោលគឺ ទី១-ការបង្ហាញពីទិន្នន័យគម្រោងវិនិយោគដែលមានអាទិភាពខ្ពស់របស់ក្រសួង ស្ថាប័ននៃរាជរដ្ឋាភិបាលកម្ពុជាដែលជាគោលនយោបាយមានចែងនៅក្នុងយុទ្ធសាស្រ្តចតុកោណដំណាក់កាលទី២ និងជាផែនទីចង្អុលផ្លូវសម្រាប់ការអនុវត្ត ផ.យ.អ.ជ. បច្ចុប្បន្នកម្ម២០០៩-២០១៣ ទី២-តម្រូវការចំណាយសរុបសម្រាប់ការអនុវត្ត ផ.យ.អ.ជ. បច្ចុប្បន្នកម្ម ២០០៩-២០១៣ (ប្រមាណជិត ៦ ៣០០ លានដុល្លារអាមេរិក) និងទី៣-បរិមាណហិរញ្ញប្បទានសហប្រតិបត្តិការដែលបានសន្យានៅក្នុងវេទិកាសហប្រតិបត្តិការអភិវឌ្ឍកម្ពុជា( វ.ស.អ.ក. )លើកទី៣-នាខែមិថុនាឆ្នាំ២០០៩-២០១៣ បានធ្វើការគូសបញ្ជាក់យ៉ាងច្បាស់លាស់រួចមកហើយអំពីវឌ្ឍនភាពដែលរាជរដ្ឋាភិបាលកម្ពុជាសម្រេចបានក្នុងដំណាក់កាលនៃការអនុវត្តបច្ចុប្បន្នកម្ម ២០០៦-២០១០ និងបញ្ហាប្រឈមថ្មីៗ ដែលមិនបានរំពឹងទុកជាមុននៃស្ថានភាពសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាកលលោកដែលអាចនឹងគំរាមកំហែងដល់អនាគតនៃសេដ្ឋកិច្ចកម្ពុជា ជាពិសេស អាចនឹងធ្វើឲ្យមានការថមថយនូវកម្លាំងជំរុញកំណើននិងការរិចរិលនៃជោគជ័យដែលសម្រេចបានរួចហើយនៅក្នុងការកាត់បន្ថយភាពក្រីក្រ។ ស្ថានភាពសេដ្ឋកិច្ចកំពុងមានការប្រែប្រួលជាវិជ្ជមានបន្ទាប់ពីរងផលប៉ះពាល់ពីការធ្លាក់ចុះនៃសេដ្ឋកិច្ចសាកលដែលកំពុងតែបន្តមានការប្រែប្រួលរហូតមកដល់ពេលបច្ចុប្បន្ននេះ ជាពិសេសសេដ្ឋកិច្ចកម្ពុជា ក៏ដូចជាចំណូលថវិកាជាតិ ហើយជាមួយនេះ ក៏មានការប្រែប្រួលលើការអនុវត្ត ក.វ.ស. បីឆ្នាំរំកិលផងដែរ។





ក.វ.ស.បីឆ្នាំរំកិល ២០១២-២០១៤ ដែលមានតម្លៃសរុបប្រចាំឆ្នាំប្រមាណ ១ ២៥០ លានដុល្លារអាមេរិក ត្រូវបានរៀបចំឡើង ដោយផ្អែកលើតម្រូវការចំណាយសរុបសម្រាប់ការអនុវត្ត ផ.យ.អ.ជ. បច្ចុប្បន្នកម្ម ២០០៩-២០១៣ (៦ ៣០០ លានដុល្លារអាមេរិក) ដើម្បីឲ្យបានស្របតាមស្ថានភាពជាក់ស្តែងនៃការប្រែប្រួលថ្លៃទំនិញនិងអតិផរណា ហើយក៏ផ្អែកលើបរិមាណហិរញ្ញប្បទានសហប្រតិបត្តិការដែលដៃគូអភិវឌ្ឍបានសន្យានៅក្នុង វ.ស.អ.ក. លើកទី៣ នាខែមិថុនា ឆ្នាំ២០១០ កន្លងទៅនេះ (ប្រមាណជិតមួយពាន់លានដុល្លារ) ផងដែរ[១]។

អង្គប្រជុំជំនាញបច្ចេកទេសបានពិនិត្យពិភាក្សាលើសេចក្តីព្រាងនេះ ហើយបានសម្រេចកែសម្រួលទម្រង់ខ្លឹមសារ ពាក្យពេចន៍ និងឃ្លាប្រយោគ និងបានស្នើដល់ក្រសួងផែនការផ្ទៀងផ្ទាត់តួលេខនិងពាក្យពេចន៍ទាំងអស់ឡើងវិញ ដើម្បីធ្វើឲ្យសេចក្តីព្រាងនេះកាន់តែល្អ។

អង្គប្រជុំជំនាញបច្ចេកទេសបានបញ្ចប់ការពិភាក្សាលើសេចក្តីព្រាងនេះទាំងស្រុង៕

[១] អត្ថបទនេះដកស្រង់ពីសេចក្តីព្រាងសេចក្តីថ្លែងហេតុនៃសេចក្តីព្រាងកម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិល។

## សេចក្តីព្រាងអនុក្រឹត្យស្តីពី

# ការអនុវត្តច្បាប់សវនកម្ម

កាលពីថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១១ វេលាម៉ោង៨:៣០នាទី នៅទីស្តីការគណៈរដ្ឋមន្ត្រីមានបើកអង្គប្រជុំជំនាញបច្ចេកទេស ក្រោមអធិបតីភាព ឯកឧត្តម **យូឃាង ថាវរិទ្ធ** សមាជិកក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) និងឯកឧត្តម **សុភ ផេង** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំដើម្បីពិនិត្យពិភាក្សាលើ **សេចក្តីព្រាងអនុក្រឹត្យស្តីពីការអនុវត្តច្បាប់សវនកម្ម** ដោយមានការអញ្ជើញចូលរួមពីសំណាក់ សមាជិក អគ្គលេខាធិការរង និងមន្ត្រីនៃក.ស.វ. សមាជិក និងមន្ត្រីនៃក្រុមប្រឹក្សាអ្នកច្បាប់ តំណាងទីស្តីការគណៈរដ្ឋមន្ត្រី តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល តំណាងខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី **សុខ អាន** មន្ត្រីជំនាញនៃទីស្តីការគណៈរដ្ឋមន្ត្រី និងតំណាងអាជ្ញាធរសវនកម្មជាតិ។

អាជ្ញាធរសវនកម្មជាតិមានភារកិច្ចអនុវត្តមុខងារសវនកម្មផ្ទៃក្រៅរបស់រាជរដ្ឋាភិបាលលើស្ថាប័នគ្រប់គ្រងដូចជាក្រសួង ស្ថាប័ន ទីភ្នាក់ងារ អាជ្ញាធរ ធនាគារជាតិ ស្ថាប័នហិរញ្ញវត្ថុរដ្ឋនិងរដ្ឋចំរុះឯកជន សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈ រដ្ឋបាលរាជធានី ខេត្ត រដ្ឋបាលមូលដ្ឋាន គម្រោងឥណទានក្រៅប្រទេស អ្នកម៉ៅការ អ្នកផ្គត់ផ្គង់ទំនិញ និងសេវាកម្មចំពោះរាជរដ្ឋាភិបាលតាមកិច្ចសន្យា និងបណ្តាលអង្គការផ្សេងៗទៀត ដែលរដ្ឋាភិបាលបានផ្តល់ជំនួយហិរញ្ញវត្ថុបន្ថែមលើទុនផ្ទាល់និងឥណទានរួមមានទាំងការលើកលែងពន្ធអាករគ្រប់ប្រភេទ ព្រមទាំងសម្បទានផ្សេងៗទៀត ទៅអង្គការដែលមិនរកប្រាក់ចំណេញនិងសហគ្រាសវិនិយោគឯកជនផងៗ

ក្នុងរយៈពេលដប់ឆ្នាំនៃប្រតិបត្តិការរបស់ខ្លួន អាជ្ញាធរសវនកម្មជាតិបានជំរុញការអនុវត្ត និងបានខិតខំផ្សព្វផ្សាយច្បាប់ស្តីពីសវនកម្មដល់ស្ថាប័នរងសវនកម្មទាំងអស់ ដើម្បីជានានូវភាពរលូនកិច្ចសហប្រតិបត្តិល្អ និងប្រសិទ្ធភាពខ្ពស់ក្នុងការអនុវត្តមុខងារសវនកម្មផ្ទៃក្រៅ។ ជាមួយគ្នានេះក្នុងការអនុវត្តការងារសវនកម្ម អាជ្ញាធរសវនកម្មជាតិបានជួបប្រទេះនូវផលវិបាកនិងបញ្ហាប្រឈមមួយចំនួនផងដែរ។





ដើម្បីជំនះបញ្ហាទាំងអស់នេះ អាជ្ញាធរសវនកម្មជាតិបានរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីការអនុវត្តច្បាប់សវនកម្មនេះឡើង ក្នុងគោលបំណងបង្កើនប្រសិទ្ធភាពការងារសវនកម្ម និងជំរុញការអនុវត្ត និងការយល់ដឹងកាន់តែទូលំទូលាយពីសំណាក់ស្ថាប័នពាក់ព័ន្ធទាំងអស់ ជាពិសេសស្ថាប័នរងសវនកម្ម(១)។

អង្គប្រជុំជំនាញបច្ចេកទេសបានពិនិត្យពិភាក្សាលើសេចក្តីព្រាងនេះ ហើយបានសម្រេចផ្តល់នូវជម្រើសបីដល់ស្ថាប័នសាមីយកទៅពិចារណា ដូចខាងក្រោមនេះ៖

១- ធ្វើវិសោធនកម្មច្បាប់ស្តីពីសវនកម្ម ឆ្នាំ២០០០។

២- អគ្គសវនករអាចចេញបទបញ្ជាផ្ទៃក្នុង សារាចរ និងការណែនាំការងារដូចចែងក្នុងមាត្រា១៥នៃច្បាប់។

៣- ធ្វើលិខិតសុំការអនុញ្ញាតពីសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីសុំចុះពិនិត្យតាមក្រសួងស្ថាប័ននីមួយៗ។

អង្គប្រជុំជំនាញបច្ចេកទេសបានផ្អាកការពិភាក្សា៕





(១) អត្ថបទនេះដកស្រង់ពីសេចក្តីព្រាងសេចក្តីថ្លែងហេតុនៃសេចក្តីព្រាងអនុក្រឹត្យស្តីពីការអនុវត្តច្បាប់សវនកម្ម។

## សេចក្តីព្រាងអនុក្រឹត្យស្តីពី

# ការផ្តល់ឋានៈសាស្ត្រាចារ្យក្នុងវិស័យអប់រំ

កាលពីថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១១ វេលាម៉ោង៨:៣០នាទី នៅទីស្តីការគណៈរដ្ឋមន្ត្រីមានបើកអង្គប្រជុំជំនាញបច្ចេកទេស ក្រោមអធិបតីភាព ឯកឧត្តម **ឆយ អូន** សមាជិកក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) និងឯកឧត្តម **ឡាំ ខា** អនុប្រធានក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សាលើ**សេចក្តីព្រាងអនុក្រឹត្យស្តីពីការផ្តល់ឋានៈសាស្ត្រាចារ្យក្នុងវិស័យអប់រំ** ដោយមានការអញ្ជើញចូលរួមពីសំណាក់ សមាជិក អគ្គលេខាធិការរង និងមន្ត្រីនៃក.ស.វ. សមាជិក និងមន្ត្រីនៃក្រុមប្រឹក្សាអ្នកច្បាប់ តំណាងទីស្តីការគណៈរដ្ឋមន្ត្រី តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល តំណាងខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី **សុខ អាន** មន្ត្រីជំនាញនៃទីស្តីការគណៈរដ្ឋមន្ត្រី និង និងតំណាងក្រសួងអប់រំ យុវជន និងកីឡា។

អនុវត្តតាមគោលនយោបាយកំណែទម្រង់វិស័យអប់រំ សំដៅឆ្លើយតបទៅនឹងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំសេចក្តីព្រាងច្បាប់ស្តីពីការអប់រំ ឆ្នាំ២០០៧។ ក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំកសាងលិខិតបទដ្ឋានគតិយុត្តនានា ដើម្បីគាំទ្រដល់ការអនុវត្តច្បាប់ស្តីពីការអប់រំឲ្យមានប្រសិទ្ធភាព ដែលក្នុងនោះក៏មានអនុក្រឹត្យស្តីពីការផ្តល់ឋានៈសាស្ត្រាចារ្យក្នុងវិស័យអប់រំនេះផងដែរ។

ការរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីការផ្តល់ឋានៈសាស្ត្រាចារ្យក្នុងវិស័យអប់រំមានគោលបំណងនិងគោលដៅ កំណត់អំពីយន្តការ នីតិវិធីនិងលក្ខខណ្ឌនៃការជ្រើសរើស និងការផ្តល់ឋានៈសាស្ត្រាចារ្យក្នុងវិស័យអប់រំ លើកកម្ពស់គុណភាពបណ្តុះបណ្តាលនៃគ្រឹះស្ថានឧត្តមសិក្សា លើកកម្ពស់ការទទួលខុសត្រូវនិងគុណវុឌ្ឍិសាស្ត្រាចារ្យ លើកតម្កើងកិត្តិយសនិងសេចក្តីថ្លៃថ្នូររបស់សាស្ត្រាចារ្យ ដើម្បីរួមចំណែកអភិវឌ្ឍធនធានមនុស្សក្នុងវិស័យអប់រំឲ្យមានគុណភាព និងប្រសិទ្ធភាពខ្ពស់(១)។



អង្គប្រជុំជំនាញបច្ចេកទេសបានពិនិត្យពិភាក្សាលើសេចក្តីព្រាងនេះ ហើយបានកត់សម្គាល់ថាក្រសួងអប់រំ យុវជន និងកីឡា គួររៀបចំសេចក្តីព្រាងនេះទៅជាផ្គត់ត្រួមតែមួយក្នុងការគ្រប់គ្រងការផ្តល់ឋានៈសាស្ត្រាចារ្យ។ ដោយសារក្រសួងអប់រំ យុវជន និងកីឡា មានការយឺតយ៉ាវក្នុងការរៀបចំសេចក្តីព្រាងនេះ ទើបក្រសួងសុខាភិបាល និងក្រសួងកសិកម្ម




វគ្គាប្រមាញ់ និងនេសាទបានចេញអនុក្រឹត្យស្តីពីការផ្តល់ឋានៈសាស្ត្រាចារ្យក្នុងវិស័យទាំងពីរនេះ។ ក្រសួងសាមីបានបញ្ជាក់ថា ក្រសួងចង់ឲ្យសេចក្តីព្រាងអនុក្រឹត្យនេះក្លាយទៅជាផ្គត់ផ្គង់តែមួយ ដើម្បីបញ្ចប់អនុក្រឹត្យផ្សេងទៀតដែលទាក់ទងនឹងការផ្តល់ឋានៈសាស្ត្រាចារ្យ។

តាមស្មារតីនេះ អង្គប្រជុំបានសម្រេចបង្កើតក្រុមការងារចង្អៀតដោយមាន តំណាងក្រុមប្រឹក្សាអ្នកច្បាប់ តំណាង ECOSOCC និងសាមីក្រសួង ដើម្បីរៀបចំជាព្រះរាជក្រឹត្យដែលជាផ្គត់ផ្គង់តែមួយក្នុងការផ្តល់ឋានៈសាស្ត្រាចារ្យក្នុងវិស័យអប់រំ។

អង្គប្រជុំជំនាញបច្ចេកទេសបានផ្អាកការពិភាក្សាលើសេចក្តីព្រាងនេះជាបណ្តោះអាសន្នសិន៕

(១) អត្ថបទនេះដកស្រង់ពីសេចក្តីព្រាងសេចក្តីថ្លែងហេតុនៃសេចក្តីព្រាងអនុក្រឹត្យស្តីពីការផ្តល់ឋានៈសាស្ត្រាចារ្យក្នុងវិស័យអប់រំ។

សេចក្តីព្រាងច្បាប់ស្តីពី

# សហជីព

កាលពីថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១១ វេលាម៉ោង៨:៣០នាទី នៅទីស្តីការគណៈរដ្ឋមន្ត្រីមានបើកអង្គប្រជុំជំនាញបច្ចេកទេស ក្រោមអធិបតីភាព ឯកឧត្តម **ឆយ អូន** សមាជិកក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) និង ឯកឧត្តម **អ៊ុំ ម៉ុនធឿន** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សាលើ**សេចក្តីព្រាងច្បាប់ស្តីពីសហជីព** ដោយមានការអញ្ជើញចូលរួមពីសំណាក់ សមាជិក អគ្គលេខាធិការរង និងមន្ត្រីនៃក.ស.វ. សមាជិក និងមន្ត្រីនៃក្រុមប្រឹក្សាអ្នកច្បាប់ តំណាងទីស្តីការគណៈរដ្ឋមន្ត្រី តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល តំណាងខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី **សុខ អាន** មន្ត្រីជំនាញទីស្តីការគណៈរដ្ឋមន្ត្រី និងតំណាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

យោងតាមអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ក្នុងវេទិការវាងរាជរដ្ឋាភិបាល និងផ្នែកឯកជនលើកទី១៤និងទី១៥ ៖

១-អនុសាសន៍ក្នុងវេទិកាលើកទី១៤កាលពីថ្ងៃ ទី២១ ខែវិច្ឆិកា ឆ្នាំ២០០៨គឺ៖ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងស្ថាប័នពាក់ព័ន្ធត្រូវរួសរាន់រៀបចំ សេចក្តីព្រាងច្បាប់ស្តីពីសហជីពឲ្យបានឆាប់ ហើយពិគ្រោះយោបល់ជាមួយដៃគូពាក់ព័ន្ធនានា ពិសេសផ្នែកឯកជន តំណាងកម្មករអង្គការពលកម្មអន្តរជាតិ(ILO)។

២-អនុសាសន៍ក្នុងវេទិកាលើកទី១៤កាលពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០០៨គឺ៖ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួង-ស្ថាប័នពាក់ព័ន្ធ ត្រូវរួសរាន់បញ្ចប់សេចក្តីព្រាងច្បាប់ស្តីពីសហជីពដាក់ជូនគណៈរដ្ឋមន្ត្រីពិនិត្យសម្រេចឲ្យបាននៅត្រីមាសទី១ ឆ្នាំ២០១១ ដើម្បីដាក់ឆ្លងសុំការអនុម័តពីស្ថាប័ននីតិប្បញ្ញត្តិក្នុងអំឡុងខែមេសា ឬ ខែឧសភា ឆ្នាំ២០១១ សំដៅធ្វើយ៉ាងណាឲ្យច្បាប់ស្តីពីសហជីពនេះ អាចប្រកាសឲ្យប្រើប្រាស់ជាផ្លូវការនៅក្នុងឆមាសទី១ ឆ្នាំ២០១១។



បន្ទាប់ពីទទួលអនុសាសន៍ដ៏ខ្ពង់ខ្ពស់នេះក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានរៀបចំសេចក្តីព្រាងច្បាប់ស្តីពីសហជីព ក្នុងគោលបំណងផ្តល់សិទ្ធិនិងសេរីភាពដល់កម្មករនិយោជិកទាំងក្នុងនិងទាំងក្រៅសហគ្រាស គ្រឹះស្ថាននិយោជក និងផ្តល់សិទ្ធិនិងសេរីភាពដល់អង្គការវិជ្ជាជីវៈរបស់កម្មករនិយោជិក និងអង្គការវិជ្ជាជីវៈរបស់និយោជកក្នុងព្រះរាជាណាចក្រកម្ពុជា។





ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ បានរៀបចំសេចក្ដីព្រាងច្បាប់ស្ដីពីសហជីពនេះ ដោយសហការជាមួយអង្គការពលកម្មអន្តរជាតិខាងការងារ(ILO) និងបានសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធនានា។ ក្នុងដំណើរការយ៉ាងសកម្ម ដើម្បីប្រមូលធាតុចូលក្នុងការកសាងសេចក្ដីព្រាងច្បាប់ស្ដីពីសហជីពនេះ ក្រសួងបានរៀបចំកិច្ចប្រជុំនិងសិក្ខាសាលាជាច្រើនលើក ៖

ក-កិច្ចប្រជុំការងារចម្រុះ(ក្រុមការងារទី៨)

ខ- សិក្ខាសាលាពិគ្រោះយោបល់ត្រីភាគី

គ-កិច្ចប្រជុំយន្តការផ្ទៃក្នុងក្រសួង(១)

អង្គប្រជុំជំនាញបច្ចេកទេសបានពិនិត្យពិភាក្សាលើសេចក្ដីព្រាងច្បាប់នេះ ហើយបានកត់សម្គាល់ឃើញថា សេចក្ដីព្រាងច្បាប់នេះសំខាន់និងចាំបាច់ណាស់ចំពោះស្ថានភាពបច្ចុប្បន្ន។ ទាំងទម្រង់និងទាំងខ្លឹមសារនៃសេចក្ដីព្រាងច្បាប់នេះមានភាពស្មុគស្មាញ ទាមទារពេលវេលាដើម្បីសិក្សាឲ្យបានលម្អិតនិងស៊ីជម្រៅ ដូច្នេះអង្គប្រជុំបានសម្រេចបង្កើតក្រុមការងាចង្អៀតដោយមាន តំណាងក្រុមប្រឹក្សាអ្នកច្បាប់ តំណាង ECOSOCC និងសាមីក្រសួង ដើម្បីរួមគ្នាពិនិត្យសិក្សាឲ្យបានច្បាស់លាស់ងាយស្រួលក្នុងការដាក់ឆ្លងកិច្ចប្រជុំបច្ចេកទេស។ តំណាងក្រសួងសាមីបានឯកភាព ក៏ប៉ុន្តែសុំឲ្យបានលឿន ព្រោះសេចក្ដីព្រាងច្បាប់នេះយឺតជាងពេលវេលាគ្រោងទុកទៅហើយ។

អង្គប្រជុំជំនាញបច្ចេកទេសបានផ្អាកការពិភាក្សាលើសេចក្ដីព្រាងនេះជាបណ្ដោះអាសន្នសិន៕

(១) អត្ថបទនេះដកស្រង់ពីសេចក្ដីព្រាងសេចក្ដីថ្លែងហេតុនៃសេចក្ដីព្រាងច្បាប់ស្ដីពីសហជីព។

# សកម្មភាពផ្សេងៗទៀតរបស់ឯកឧត្តម យឹម ណុលឡា ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែវិច្ឆិកា ឆ្នាំ២០១១

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ០២/១១/១១<br>ម៉ោង ០៨ : ០០ នាទី | ចូលរួមជាកិត្តិយសក្នុងពិធីបើកការដ្ឋានសាងសង់ស្ពានជ្រោយចង្វាទី ២ (ឆ្លងកាត់ទន្លេសាប) ប្រវែង ៧១៩ ម៉ែត្រ ក្រោមកម្ចីឥណទានពីរដ្ឋាភិបាល នៃសាធារណរដ្ឋប្រជាមានិតចិន ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវកិត្តិព្រឹទ្ធបណ្ឌិត នៅភូមិ៣ សង្កាត់ជ្រោយចង្វា ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ។ |
| ២ | ០៣/១១/១១<br>ម៉ោង ០៨ : ៣០ នាទី | ដឹកនាំកិច្ចប្រជុំក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដើម្បីវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែកញ្ញា ឆ្នាំ២០១១ នៅទីស្តីការគណៈរដ្ឋមន្ត្រី ។ |
| ៣ | ០៣/១១/១១<br>ម៉ោង ១៥ : ០០ នាទី | ដឹកនាំកិច្ចប្រជុំគណៈកម្មការបច្ចេកទេស ដើម្បីសម្របសម្រួលការអនុវត្តគម្រោងវិនិយោគសាងសង់សារមន្ទីរសព្វទស្សន៍ (Grand Panorama Museum) ក្នុងខេត្តសៀមរាប នៅទីស្តីការគណៈរដ្ឋមន្ត្រី ។ |
| ៤ | ០៤/១១/១១<br>ម៉ោង ០៩ : ០០ នាទី | ដឹកនាំកិច្ចប្រជុំ ដើម្បីពិភាក្សាអំពីកិច្ចដំណើរការរបស់អគ្គលេខាធិការដ្ឋាន ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ នៅទីស្តីការគណៈរដ្ឋមន្ត្រី ។ |
| ៥ | ០៨/១១/១១<br>ម៉ោង ០៨ : ៣០ នាទី | ដឹកនាំកិច្ចប្រជុំអនុក្រុមសិក្សាស្រាវជ្រាវ ដើម្បីពិភាក្សាលើប្រធានបទ លទ្ធភាពបង្កើនចំណូលថវិកាជាតិ នៅទីស្តីការគណៈរដ្ឋមន្ត្រី ។ |
| ៦ | ០៨/១១/១១<br>ម៉ោង ១៥ : ៣០ នាទី | ជួបប្រជុំពិភាក្សាការងារជាមួយតំណាងក្រុមហ៊ុន Mansudae New Tech Corporation Ltd នៅបន្ទប់ឯកឧត្តមប្រធាន (ECOSOCC) នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៧ | ០៩/១១/១១<br>ម៉ោង ០៧ : ៣០ នាទី | ចូលរួមជាកិត្តិយសក្នុងពិធីដុតទៀនជ័យ ខួបអនុស្សាវរីយ៍លើកទី ៥៨ ទិវាបុណ្យឯករាជ្យជាតិ ៩ វិច្ឆិកា ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុត ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត នៅវិមានឯករាជ្យ។ |
| ៨ | ១៤/១១/១១<br>ម៉ោង ០៨ : ០០ នាទី | ចូលរួមជាកិត្តិយសក្នុងពិធីសម្ពោធបើកឲ្យប្រើប្រាស់ជាផ្លូវការកំណាត់ផ្លូវជាតិលេខ ៣ ជំហានទី ២ ប្រវែង ១៣៤.៨០គ.ម (ចោមចៅ-កំពត) និងបើកការដ្ឋានស្តារឡើងវិញ(ផ្លូវជាតិលេខ ៣១, ៣៣ ផ្លូវខេត្តលេខ ១១៧ និងផ្លូវវាងទីរួមខេត្តកំពត) ក្រោមកម្ចីឥណទានពីរដ្ឋាភិបាល នៃសាធារណរដ្ឋកូរ៉េ និងបើកការដ្ឋានស្តារឡើងវិញកំណាត់ផ្លូវជាតិលេខ ៣៣ (កំពង់ត្រាច-ព្រំដែនកម្ពុជា-វៀតណាម) ក្រោមកម្ចីឥណទានពីធនាគារអភិវឌ្ឍន៍អាស៊ី និងជំនួយឥតសំណងរបស់ទីភ្នាក់ងារអូស្ត្រាលី ដើម្បីអភិវឌ្ឍន៍អន្តរជាតិ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវកិត្តិព្រឹទ្ធបណ្ឌិត នៅភូមិព្រៃព្រីងខាងត្បូង សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ ។ |

# សកម្មភាពផ្សេងៗរបស់ឯកឧត្តម យឹម ណុលឡា ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែវិច្ឆិកា ឆ្នាំ២០១១ (ត)

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ៩ | ១៤/១១/១១ ម៉ោង ១៥:៣០នាទី " | ដឹកនាំអង្គប្រជុំ ដើម្បីពិនិត្យ និងពិភាក្សាលើ៖<br>១-សេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីការបង្កើតគណៈស្ថាបត្យករកម្ពុជា។<br>២-សេចក្តីព្រាងអនុក្រឹត្យស្តីពីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ។<br>៣-បញ្ហាផ្សេងៗ ។<br>ដើម្បីត្រៀមប្រជុំជាមួយ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី ។ |
| ១០ | ១៥/១១/១១ ម៉ោង ១៥:៣០នាទី | ដឹកនាំកិច្ចប្រជុំគណៈកម្មការសាងសង់អគារសារមន្ទីរសព្វទស្សន៍ ជាមួយនឹងក្រុមហ៊ុនម៉ាន់ស៊ូដេញ្ញតិច នៅទីស្តីការគណៈរដ្ឋមន្ត្រី ។ |
| ១១ | ១៦/១១/១១ ម៉ោង ០៨:០០នាទី | ចូលរួមជាកិត្តិយសក្នុងពិធីជូនដំណើរគណៈប្រតិភូជាន់ខ្ពស់ នៃរាជរដ្ឋាភិបាលកម្ពុជា ដឹកនាំដោយសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវកិត្តិព្រឹទ្ធបណ្ឌិត នឹងអញ្ជើញទៅចូលរួមកិច្ចប្រជុំកំពូលអាស៊ានលើកទី ១៩ និងកិច្ចប្រជុំកំពូលពាក់ព័ន្ធនានា នៅកោះបាលី សាធារណរដ្ឋឥណ្ឌូនេស៊ី នៅព្រលានយន្តហោះអន្តរជាតិភ្នំពេញ ។ |
| ១២ | ១៧/១១/១១ ម៉ោង ០៩:០០នាទី | ចូលរួមប្រជុំគណៈកម្មការព្រលានយន្តហោះ នៅព្រលានយន្តហោះអន្តរជាតិភ្នំពេញ។ |
| ១៣ | ២៣/១១/១១ ម៉ោង ០៧:៣០នាទី | ចូលរួមក្នុងវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន លើកទី ១៦ ដើម្បីវាយតម្លៃលើការអនុវត្ត និងកំណត់ភារកិច្ចត្រូវអនុវត្តបន្ត ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅទីស្តីការនាយករដ្ឋមន្ត្រី ។ |
| ១៤ | ២៣/១១/១១ ម៉ោង ១៨:៣០នាទី | ចូលរួមជាកិត្តិយសក្នុងរាត្រីស្រមោលស នៅសណ្ឋាគារសូហ្វីតែល តាមការអញ្ជើញពីស្ថានទូតប្រទេសបារាំង ។ |
| ១៥ | ២៤/១១/១១ ម៉ោង ១៥:១៥នាទី | ដឹកនាំអង្គប្រជុំ ដើម្បីពិនិត្យ និងពិភាក្សាលើ៖<br>១-សេចក្តីព្រាងច្បាប់ស្តីពីលទ្ធកម្មសាធារណៈ ។<br>២-សេចក្តីព្រាងអនុក្រឹត្យស្តីពីការផ្តល់ឋានៈសាស្ត្រាចារ្យក្នុងវិស័យកសិកម្ម ។<br>៣-បញ្ហាផ្សេងៗ ។<br>ដើម្បីត្រៀមប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី ។ |
| ១៦ | ២៤/១១/១១ ម៉ោង ១៦:៣០នាទី | ចូលរួមជាមួយ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ក្នុងការអនុញ្ញាតឲ្យ ឯកឧត្តម Ri in sok ឯកអគ្គរដ្ឋទូត នៃសាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យកូរ៉េ ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ចូលជួបសម្តែងការគួរសម និងជម្រាបលា នៅទីស្តីការគណៈរដ្ឋមន្ត្រី ។ |

# សកម្មភាពផ្សេងទៀតរបស់ឯកឧត្តម យឹម ណុលឡា ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែវិច្ឆិកា ឆ្នាំ២០១១ (តចប់)

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១៧ | ២៥/១១/១១ ម៉ោង ០៨:៣០នាទី " | ចូលរួមក្នុងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពិភាក្សាលើរបៀបវារៈ ដូចខាងក្រោម៖<br>១-សេចក្តីព្រាងយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១១-២០២០ ។<br>២-សេចក្តីព្រាងច្បាប់ស្តីពីលទ្ធកម្មសាធារណៈ ។<br>៣-សេចក្តីព្រាងច្បាប់ស្តីពីការកំណត់ចំនួនអាសនៈរដ្ឋសភាសម្រាប់នីតិកាលទី៥ ។<br>៤-សេចក្តីព្រាងអនុក្រឹត្យស្តីពីការផ្តល់ឋានៈសាស្ត្រាចារ្យក្នុងវិស័យកសិកម្ម ។<br>៥-បញ្ហាផ្សេងៗ ។<br>នៅទីស្តីការនាយករដ្ឋមន្ត្រី ។ |
| ១៨ | ២៧/១១/១១ ម៉ោង ១៧:២០នាទី | ចូលរួមជាកិត្តិយសក្នុងពិធីបើកកិច្ចប្រជុំលើកទី ១១ នៃរដ្ឋភាគីអនុសញ្ញាអូតាវ៉ា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន នៅទីស្តីការនាយករដ្ឋមន្ត្រី ។ |
| ១៩ | ២៨/១១/១១ ម៉ោង ០៨:០០នាទី | ចូលរួមជាកិត្តិយសក្នុងពិធីបើកសន្និសីទថ្នាក់តំបន់ ស្តីពី "ប្រទេសកម្ពុជា ឡាវ មីយ៉ាន់ម៉ា វៀតណាម និងសហគមន៍សេដ្ឋកិច្ចអាស៊ាន ឆ្នាំ២០១៥ : ការបង្រួតបង្រួមគម្លាតនៃការអភិវឌ្ឍន៍" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅសណ្ឋាគារឡឺរ៉ូយ៉ាល់ ។ |
| ២០ | ២៩/១១/១១ ម៉ោង ០៧:៣០នាទី | ចូលរួមជាកិត្តិយស ជាសមាជិកក្នុងពិធីសច្ចាប្រណិធាន និងបំពាក់កន្សែងជូនកាយរឹទ្ធិ រាជធានីភ្នំពេញ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានកាយរឹទ្ធិជាតិកម្ពុជា និងលោកជំទាវ នៅបរិវេណពហុកីឡាដ្ឋានជាតិអូឡាំពិក ។ |

# សកម្មភាពដទៃទៀតរបស់ ឯកឧត្តម អនុប្រធាន និង សមាជិក-សមាជិកា ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែវិច្ឆិកា ឆ្នាំ២០១១

## ឯកឧត្តម យឹម ណុលសន អនុប្រធាន

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ០២/១១/១១ | ចូលរួមជាកិត្តិយសក្នុងពិធីចុះហត្ថលេខាលើវិសោធនកម្មទី៣ នៃកិច្ចព្រមព្រៀងជំនួយ រវាងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា និងសហរដ្ឋអាមេរិក សម្រាប់កម្មវិធីកំណើនសេដ្ឋកិច្ចរបស់ USAID ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ២ | ០៧/១១/១១ | ជួបប្រជុំជាមួយបេសកកម្ម ADB ផ្នែកពិនិត្យ និងវាយតម្លៃគម្រោង នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៣ | ១៤/១១/១១ | ដឹកនាំអង្គប្រជុំរបស់ក្រុមការងារ RIA ស្តីពីការបង្ហាញរបាយការណ៍ដំបូងរបស់ទីប្រឹក្សា នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៤ | ២១/១១/១១ | ចូលរួមវគ្គបណ្តុះបណ្តាលក្រុមការងារអនុវត្តគម្រោងវាយតម្លៃផលប៉ះពាល់លិខិតបទដ្ឋានគតិយុត្ត នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៥ | ២៨/១១/១១ | ចូលរួមជាកិត្តិយសក្នុងពិធីបើកសន្និសីទថ្នាក់តំបន់ ស្តីពី "ប្រទេសកម្ពុជា ឡាវ មីយ៉ាន់ម៉ា វៀតណាម និងសហគមន៍សេដ្ឋកិច្ចអាស៊ាន ឆ្នាំ២០១៥ : ការបង្កិតឲ្យជិតគ្នានូវគម្លាតនៃការអភិវឌ្ឍន៍" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅសណ្ឋាគារឡឺរ៉ូយ៉ាល់ ។ |
| ៦ | ២៩/១១/១១ | ចូលរួមជាកិត្តិយស ជាសមាជិកក្នុងពិធីសច្ចាប្រណិធាន និងបំពាក់កន្សែងជូននវកាយរឹទ្ធិ រាជធានីភ្នំពេញ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានកាយរឹទ្ធិជាតិកម្ពុជា និងលោកជំទាវ នៅបរិវេណពហុកីឡាដ្ឋានជាតិអូឡាំពិក ។ |

# សកម្មភាពដទៃទៀតរបស់ ឯកឧត្តម អគ្គលេខាធិការ ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែវិច្ឆិកា ឆ្នាំ២០១១

## ឯកឧត្តម ង៉ាន់ ភិរុណ អគ្គលេខាធិការ

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ០២/១១/១១ | ចូលរួមជាកិត្តិយសក្នុងពិធីចុះហត្ថលេខាលើវិសោធនកម្មទី៣ នៃកិច្ចព្រមព្រៀងជំនួយ រវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងសហរដ្ឋអាមេរិក សម្រាប់កម្មវិធីកំណើនសេដ្ឋកិច្ចរបស់ USAID ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី ។ |
| ២ | ២៥/១១/១១<br>" | ចូលរួមក្នុងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពិភាក្សាលើរបៀបវារៈដូចខាងក្រោម៖<br>១-សេចក្តីព្រាងយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១១-២០២០ ។<br>២-សេចក្តីព្រាងច្បាប់ស្តីពីលទ្ធកម្មសាធារណៈ ។<br>៣-សេចក្តីព្រាងច្បាប់ស្តីពីការកំណត់ចំនួនអាសនៈរដ្ឋសភាសម្រាប់នីតិកាលទី៥ ។<br>៤-សេចក្តីព្រាងអនុក្រឹត្យស្តីពីការផ្តល់ឋានៈសាស្ត្រាចារ្យក្នុងវិស័យកសិកម្ម ។<br>៥-បញ្ហាផ្សេងៗ ។<br>នៅទីស្តីការនាយករដ្ឋមន្ត្រី ។ |

# ព្រឹត្តិបត្រព័ត៌មាន

| | | |
|---|---|---|
| នាយកគ្រប់គ្រងទូទៅ ៖ | ឯកឧត្តម គឹម ស៊ុយសាមេឡេន | អនុប្រធាន គ.ស.វ. |
| និពន្ធនាយក ៖ | ឯកឧត្តម ប៉ាន ពិរុណ | អគ្គលេខាធិការ គ.ស.វ. |
| និពន្ធអក្ខរាវិរុទ្ធ ៖ | ឯកឧត្តម ចេង ត្រេងរឹ | អគ្គលេខាធិការរង គ.ស.វ. |
| វិភាគស្ថានភាពសេដ្ឋកិច្ច ៖ | ឯកឧត្តម អឹម សារិត្ត | សមាជិកបម្រុង គ.ស.វ. |
| បច្ចេកទេសកុំព្យូទ័រ និងសម្របសម្រួល ៖ | លោក ស៊ុយ វាសនា | ប្រធានការិយាល័យ គ.ស.វ. |
| យកព័ត៌មាន និងថតរូប ៖ | លោក ម៉ុត កក្កដា | មន្ត្រី គ.ស.វ. |
| ទំនាក់ទំនង និងបោះពុម្ពផ្សាយ ៖ | លោក អ៊ុក ឆាយា | ជំនួយការទេសរដ្ឋមន្ត្រីប្រធាន គ.ស.វ. |



## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌


ទូរស័ព្ទលេខ: ០២៣ ២១១ ៩៤៣ ០១៦ ៣០៧ ៣៣០

ទូរសារលេខ: ០២៣ ២១១ ៩៤៣

E-mail: veasna@live.in